# ព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ច មេគង្គ-ជប៉ុន លើកទី២ នៅទីក្រុង ដា ណាំង ប្រទេសវៀតណាម

កាលពីថ្ងៃទី ២៥ និង២៦ ខែ សីហា ឆ្នាំ ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជា រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសំរាប់កម្ពុជា បានដឹកនាំគណៈប្រតិភូអន្តរក្រសួងមកពី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសាធារណៈការ និងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ទៅចូលរួមកិច្ចប្រជុំ ជាមួយតំណាងផ្នែកធុរៈកិច្ច និងវិនិយោគ ពីបណ្តាប្រទេសមេគង្គ និងប្រទេសជប៉ុន មានប្រមាណ១០០ នាក់។ នេះគឺជាកិច្ច ប្រជុំលើកទី២ ថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ច មេគង្គ-ជប៉ុន ដែលបានប្រារព្ធធ្វើនៅទីក្រុង ដា ណាំង ប្រទេសវៀតណាម ដើម្បីពិភាក្សាពីការ អភិវឌ្ឍន៍តំបន់មេគង្គ និងការធ្វើឱ្យប្រសើរឡើងនូវ បរិយាកាសវិនិយោគ និងពាណិជ្ជកម្មនៅក្នុងតំបន់មេគង្គ ដោយមានការចូលរួមផ្តល់អនុសាសន៍ដោយវិស័យឯកជនដែលមានវត្តមាននៅក្នុងតំបន់នេះ ។

នៅក្នុងកិច្ចប្រជុំនេះវិស័យឯកជនបានផ្តល់អនុសាសន៍ឱ្យរដ្ឋាភិបាលបណ្តាប្រទេសមេគង្គ និងជប៉ុនជួយសម្រួល និងបង្កើនល្បឿនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កិច្ចសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងវិនិយោគ និងសម្រួលបែបបទ និងនីតិវិធីគយឱ្យងាយនិងប្រហាក់ប្រហែលគ្នា ការបំពាក់ឧបករណ៏បច្ចេកវិទ្យាពតិមានដល់ភ្នាក់ងារតាមព្រំដែន និងបណ្តុះបណ្តាលមន្ត្រីនៅតាមព្រំដែន ការជួយគាំទ្រដល់ការអភិវឌ្ឍន៍សហគ្រាសតូច និងមធ្យមព្រមទាំង ឧស្សាហកម្មនានារួមទាំង កសាងប្រព័ន្ធផ្តល់ហិរញ្ញប្បទានផងដែរ។ ជាមួយនោះ វិស័យឯកជនបានស្នើឱ្យជួយពង្រឹងដល់វិស័យសេវាកម្មនានាដែល កំពុងធ្វើអាជីវកម្ម និងដែល បានបង្កើតមុខរបរថ្មីៗដែលកំពុងមានសក្តានុពលនៅក្នុងតំបន់មេគង្គ ។

បន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងលម្អិតលើអនុសាសន៏លើកស្នើដោយវិស័យឯកជន ព្រមទាំងបានធ្វើការផ្ទៀងផ្ទាត់ជាមួយកម្មវិធី និងផែនការអភិវឌ្ឍន៏នៃអង្គការអភិវឌ្ឍន៍ដ៏ទៃទៀត ដូចជា អាស៊ាន, មហាអនុតំបន់មេគង្គជាដើម និងពិនិត្យលើលទ្ធភាពផ្តល់ ហិរញ្ញប្បទានរួចមក រដ្ឋមន្ត្រីមេគង្គ និងជប៉ុន បានទទួលយកអនុសាសន៍ជាច្រើន យកទៅធ្វើជាធាតុចូលសម្រាប់កសាងជាផែនការ សកម្មភាពនៃគំនិតផ្តួចផ្តើមសម្រាប់កិច្ចសហប្រតិបត្តិការរវាង មេគង្គ-ជប៉ុន ដែលស្របតាមស្មារតីនិងការណែនាំនៃកិច្ចប្រជុំ កំពូលរវាងនាយករដ្ឋមន្ត្រី មេគង្គ-ជប៉ុន ដែលបានប្រារព្ធធ្វើនៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅទីក្រុងតូក្យូប្រទេសជប៉ុន ដែលពេលនោះ ថ្នាក់ដឹកនាំកំពូល មេគង្គ-ជប៉ុន បានប្តេជ្ញាកសាងតំបន់មេគង្គ តាមរយៈការសន្យាផ្តល់ហិរញ្ញប្បទានដោយភាគី ជប៉ុន និងឯកភាពលើផែនការសកម្មភាព៦៣ ចំណុចសម្រាប់អភិវឌ្ឍន៏តំបន់មេគង្គ ផងដែរ។

រដ្ឋមន្ត្រីមេគង្គ-ជប៉ុន បានឯកភាពលើផែនការសកម្មភាពមេគង្គ- ជប៉ុន ដែលគ្របដណ្តប់លើសរសរស្តម្ភសំខាន់ៗចំនួន៤ គឺ ១- កសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលជួយតភ្ជាប់តំបន់មេគង្គ និងជួយសម្រួល ដល់ការធ្វើវិនិយោគ ពាណិជ្ជកម្ម និងដឹកជញ្ជូន ២- រៀបចំក្របខ័ណ្ឌ និងកម្មវិធីសម្រួលពាណិជ្ជកម្ម និងកសាងមូលដ្ឋានភស្តុភារ ៣- កម្មវិធីគាំទ្រដល់ការអភិវឌ្ឍន៍ សហគ្រាស ធនតូច និងមធ្យម ដែលរួមមាន ការសាងសង់ តំបន់សេដ្ឋកិច្ចពិសេស និងតភ្ជាប់បណ្តាញភស្តុភារ ការជួយផ្តល់ហិរញ្ញប្បទាន និងកសាងធនធានមនុស្ស និង ៤- ពង្រឹង ដល់វិស័យសេវាកម្ម និងឧស្សាហកម្មថ្មីៗ ដែលជួយបង្កើតការងារ និងប្រភពចំណូល ដល់ប្រជាជន ហើយក៏បានបញ្ចូលគំនិត ថ្មីស្តីពីការកសាងឧស្សាហកម្ម និងការពារបរិស្ថានជាមួយគ្នាផងដែរ ។

រដ្ឋមន្ត្រីបានឯកភាពថា នឹងដាក់ផែនការសកម្មភាពនេះជូនទៅថ្នាក់ដឹកនាំកំពូលមេគង្គ-ជប៉ុន នៅខែតុលា ឆ្នាំ ២០១០ នៅឯកិច្ចប្រជុំនាទីក្រុងហាណូយ ដើម្បីផ្តល់ការអនុម័ត ។ បន្ទាប់ពីនេះ ក្រុមការងារជំនាញនឹងរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពតាមវិស័យនីមួយៗជូនរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំកំពូលពិនិត្យក្នុងរយៈពេល៦ខែម្តង ដែលក្នុងនោះក៏មានការពិនិត្យកែសម្រួល និងធ្វើ បច្ចុប្បន្នភាពផែនការសកម្មភាពនេះជាប្រចាំ ដើម្បីឱ្យស្របតាមសភាការណ៏អភិវឌ្ឍន៏ នៅក្នុងតំបន់ និងក្នុងពិភពលោកផងដែរ ។ កម្ពុជានឹងទទួលបានអត្ថប្រយោជន៏ ជាច្រើនពីការអនុវត្តផែនការសកម្មភាពនេះ ដោយសារផ្លូវថ្នល់រវាងក្រុងភ្នំពេញ

ស្ពាននាក់ លឿង ការពង្រីកកំពង់ផែ គម្រោងសាង សង់រោងចក្រកែច្នៃ ការផ្តល់ប្រភពឥណទានដល់សហគ្រាសតូច និងមធ្យម ការបណ្តុះ បណ្តាលធនធានមនុស្ស ជាដើម នឹងត្រូវបាន ជួយដោយភាគីជប៉ុន ។